ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១០

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ខែ ធ្នូ ឆ្នាំ២០១០

...ការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៥៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្តម សុត សាម ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ព.ល. ១០១២.៩៦៩

លេខ:៨៤៨ ច.ល
[illegible] ចម្លងចែក
[illegible] ភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១០
[illegible] រាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១០

[illegible] ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានបញ្ឈប់មុខងារឯកឧត្តម ចំនួន ០៩ រូប ពីទីប្រឹក្សា និងជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា តាមសំណើសាមីខ្លួន ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម	ហុង	ពីរ	ទីប្រឹក្សា
២- ឯកឧត្តម	វិញ	ហ៊ួរ	ទីប្រឹក្សា
៣- ឯកឧត្តម	ឡុច	សារ៉េត	ទីប្រឹក្សា
៤- ឯកឧត្តម	ងួន	ឃាង	ទីប្រឹក្សា
៥- ឯកឧត្តម	ស្រេង	គង់	ទីប្រឹក្សា
៦- ឯកឧត្តម	ជាត់	ប៊ុន	ទីប្រឹក្សា
៧- ឯកឧត្តម	ហាក់	ប៊ុនថា	ទីប្រឹក្សា
៨- ឯកឧត្តម	លឹម	ហ៊ុយឡេង	ទីប្រឹក្សា
៩- ឯកឧត្តម	តា	ធី	ជំនួយការ

មាត្រា២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១០

៣រល. ១០១២. ៩៧០

លេខ ៨៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១០
អគ្គលេខាធិការរងគណៈរដ្ឋមន្ត្រី

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

ឯកឧត្តម សូខ ផេង

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល. ១០១២.៩៧២

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០

លេខៈ៨៤៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៥៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

លោក គិត លីច័ន្ទផាន់ណា

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ចករ

ពរ.ល. ១០១៤.៩៧៥

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១០

លេខៈ៨ ៥៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានបញ្ឈប់មុខងារឯកឧត្តម ចំនួន០២ រូប ពីទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា តាមសំណើសាមីខ្លួន ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម ខួរ គឹមបាក់

២- ឯកឧត្តម គ្រាង យូ

មាត្រា២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១០១២.៩៧៦

លេខ: ៨៥៣ ច.ល
ថ្មើថ្លៃចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១០

ស៊ុំ ម៉ិនកេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/១២១០/៩៦១

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយនគរបាលជាតិ និង មន្ត្រីរាជការស៊ីវិលនៅខេត្តបាត់ដំបង ចំនួន ១២ រូប ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចបំរើជាតិមាតុភូមិ និងមានស្មារតីទទួលខុសត្រូវខ្ពស់ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

នូវ

ក- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-ឯកឧត្តមឧត្តមសេនីយ៍ឯក **សុខ ផល** អត្តលេខ ០០៥១
២-ឯកឧត្តមឧត្តមសេនីយ៍ទោ **ឃុន សំបូរ** អត្តលេខ ០៦៩៣

ខ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** :

១-លោកឧត្តមសេនីយ៍ត្រី **ឌី វិជ្ជា** អត្តលេខ ០១២៧៨
២- លោក **ចៅ ប្រុច**
៣-លោកឧត្តមសេនីយ៍ត្រី **យឹម សារុំ** អត្តលេខ ០២៣៩
៤-លោកឧត្តមសេនីយ៍ត្រី **គង់ សារ៉ន** អត្តលេខ ០៧៣៦
៥-លោកឧត្តមសេនីយ៍ត្រី **សូ ម៉ុងឈឿន** អត្តលេខ ០២៤០
៦-លោកឧត្តមសេនីយ៍ត្រី **នៅ សុផា** អត្តលេខ ០១៣៨៣

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

៧- លោក ឈាង តឿន

៨- លោក ស្រេង ស្រ៊ាង

៩-លោកវរសេនីយ៍ទោ ស៊ុំ សំណាប់ អត្តលេខ ០១៣៨៩

១០- លោក ស៊ុំ ចិសេស

ព្រះហស្តលេខា និងព្រះរាជលញ្ជករ

នរោត្តម សីហមុនី

៣រល. ១០១២. ៩៧៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០

លេខ: ៨៥៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុំ ចិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ២.២៨២ ហិកតា

ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកសំបូរ ខេត្តក្រចេះ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា១:-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ២.២៨២ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំរលួសមានជ័យ ស្រុកសំបូរ ខេត្តក្រចេះ ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាលេខ ២២១៣ ចណ.ក្រច ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ របស់សាលាខេត្តក្រចេះ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា២:-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

មាត្រា៣:-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១៦៥..អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៧.០០០ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកសន្ទុក និងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា១:-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៧.០០០ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកសន្ទុក និងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដើម្បីធ្វើការវិនិយោគដាំដើមអាកាស្យា និងប្រភេទឈើផ្សេងៗ ដូចមានក្នុងផែនទី និង និយាមកាលេខ ០៤បជ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ និងលេខ ៣៦៨ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១០ របស់សាលាខេត្ត កំពង់ធំ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២:-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្រប តាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល។

មាត្រា៣:-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៦៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.៧៨៤ ហិកតា
ស្ថិតនៅភូមិសាស្ត្រ ស្រុកសន្ទុក ខេត្តកំពង់ធំ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា១:-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៩.៧៨៤ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំបឹងល្វា និងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមការលេខ ១៥៨សណ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៥ របស់សាលាខេត្តកំពុងធំ ជាឧបសម្ព័ន្ធនៃ អនុក្រឹត្យនេះ ។

មាត្រា២:-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្រប តាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល។

មាត្រា៣:-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..២៦៣..អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន និងការបង្កើនបៀវត្សរ៍សុទ្ធសាធរបស់មន្ត្រីរាជការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្គស្លាប់ បាត់ខ្លួន និងពិការ

-បានឃើញអនុក្រឹត្យលេខ ១៨៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការកែសម្រួលប្រាក់បៀវត្សរ៍មូលដ្ឋានរបស់កងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលប្រាក់បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីនគរបាលជាតិ

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ស្តីពីរបបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេច

មាត្រា ១.

អនុក្រឹត្យនេះមានគោលដៅកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋាន ពី ៨៧០ (ប្រាំបីរយចិតសិប) រៀល ទៅ ១០៥០ (មួយពាន់ហាសិប) រៀល របស់មន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងបង្កើន ២០ (ម្ភៃ) ភាគរយ នៃបៀវត្សរ៍សុទ្ធសាធ របស់និវត្តជន ជនបាត់បង់សមត្ថភាពការងារ ជនបាត់បង់សមត្ថភាពពលកម្ម ជនពិការដែលជាអតីតយុទ្ធជន។

មាត្រា ២.

តម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋាន និងការបង្កើនបៀវត្សរ៍សុទ្ធសាធដូចមានចែងក្នុងមាត្រា ១ ខាងលើត្រូវចាប់អនុវត្តពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១១ តទៅ។

មាត្រា ៣.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរផលាធានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧, ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ :

ឯកតា:លានរៀល

ជំពូក	បរិយាយ	ច្បាប់ហិរញ្ញវត្ថុ	និយ័តកម្ម		ឥណទានថ្មី
			កើន	ថយ	
	និយ័តកម្មចេញ				
	៩៩- ចំណាយមិនទាន់បែងចែក			1.005.074	
៦៦	បន្ទុកហិរញ្ញវត្ថុ	140.000	-	140.000	0
៦៥	ឧបត្ថម្ភធន និងជំនួយសង្គម	255.074	-	255.074	0
០៩	ចំណាយមិនបានគ្រោងទុក	369.675	-	220.000	149.675
១៦	ការទូទាត់ប្រាក់ខ្ចី និងបំណុលប្រហាក់ប្រហែល	180.000	-	180.000	0
២៧	អចលកម្មហិរញ្ញវត្ថុផ្សេងៗ	210.000		210.000	0
	និយ័តកម្មចូល				
	១០- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ		1.005.074		
៦១	សេវាខាងក្រៅ	4.283,5	190.000	-	194.283,5
៦៦	បន្ទុកហិរញ្ញវត្ថុ	0	140.000	-	140.000
៦៥	ឧបត្ថម្ភធន និងជំនួយសង្គម	9.030	255.074	-	264.104
៦៣	ពន្ធ និងអាករ	150	30.000	-	30.150
១៦	ការទូទាត់ប្រាក់ខ្ចី និងបំណុលប្រហាក់ប្រហែល	0	180.000	-	180.000
២៧	អចលកម្មហិរញ្ញវត្ថុផ្សេងៗ	0	210.000	-	210.000

មាត្រា ២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ធ្នូ ឆ្នាំ ២០១០

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ
តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧, ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១: ឥណទានចំណាយថវិកាថ្នាក់ជាតិ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ត្រូវបានបែងចែកតាមក្រសួងនីមួយៗ តាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងតាមជំពូកនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ហើយដែលត្រូវបានបែងចែកជាថវិកាកម្មវិធី និងថវិកាមិនមែនកម្មវិធីសម្រាប់ក្រសួងសាកល្បងទាំង ៨ ដូចមានក្នុងតារាងភ្ជាប់ជាមួយអនុក្រឹត្យនេះ ។

មាត្រា ២: ការបែងចែកឥណទានចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនី និង អនុគណនីត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី-រដ្ឋលេខាធិការ ដែលជាប្រធានក្រសួង-ស្ថាប័ន អភិបាលនៃគណៈអភិបាលគ្រប់រាជធានីខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
ដាក់ឡាយព្រះហស្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧០ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការបែងចែកចំណូលថវិកាថ្នាក់ជាតិ
តាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧, ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្ដីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្ដីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

<u>សម្រេច</u>

<u>មាត្រា ១</u>: ឥណទានចំណូលថវិកាថ្នាក់ជាតិ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ត្រូវបានបែងចែកតាមក្រសួងនីមួយៗ តាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ ដែលមានប្រភពចំណូល និងតាមជំពូកនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដូចមានក្នុងតារាងភ្ជាប់ជាមួយអនុក្រឹត្យនេះ ។

<u>មាត្រា ២</u>: ចំណូលទាំងអស់នេះ ត្រូវប្រមូលដើម្បីគុណប្រយោជន៍ដល់ថវិកាថ្នាក់ជាតិ និងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការបែងចែកចំណូលនៃជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

<u>មាត្រា ៣</u>: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី-រដ្ឋលេខាធិការ ដែលជាប្រធានក្រសួង-ស្ថាប័ន អភិបាលនៃគណៈអភិបាលគ្រប់រាជធានីខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ៨ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១២៣៤ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ចំនួន ០៥ គ្រឿង ជូនបុគ្គលិកអង្គការអន្តរជាតិ ចំនួន ០៥រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញការងារ ជួយដល់មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តសៀមរាប និង ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម៖

១-	លោក	សុខ សុផន	ប្រធានគម្រោងស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តសៀមរាប
២-	លោក	ផន ហឿម	ប្រធានគម្រោងស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តតាកែវ
៣-	កញ្ញា	ឆម្ម ចំនួម៉ូលីនា	អនុប្រធានកម្មវិធីបង្ការ និងស្តារលទ្ធភាពពលកម្មកាយសម្បទាអង្គការ HIB
៤-	លោក	កែវ រដ្ឋា	ប្រធានមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តសៀមរាប
៥-	អ្នកស្រី	អ៊ុំ មួយ	ប្រធានរដ្ឋបាលមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តតាកែវ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១២៣៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសហមេត្រី តាមលំដាប់ថ្នាក់ ចំនួន ០៩ គ្រឿង ជូនអង្គភាពក្រសួង អង្គការ និងតំណាងអង្គការអន្តរជាតិ ដែលបានឧបត្ថម្ភគាំទ្រថវិកាក្នុងមួយឆ្នាំៗ ចំនួន៤៥០.០០០ ដុល្លារអាមេរិក ជួយដល់មណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តសៀមរាប និងខេត្តតាកែវ ដូចមានរាយនាមខាងក្រោម៖

ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទៈ

1- Ministry of Foreign Affairs of Belgium

2- Ministry of Foreign Affairs of Luxemburg

ខ-មេដាយសហមេត្រី ថ្នាក់ សេនាៈ

1- អង្គការ The Belgian Development Cooperation

2- លោក David Curtis តំណាងអង្គការ AUSAID

3- អង្គការ Europe Aid and ECHO

4- អង្គការ Norwegian People Aid

5- អង្គការ Parthenon Trust

6- អង្គការ Irish Aid

7- អង្គការ Japan International Cooperation

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ ... ឆ្នាំ ២០១០

អន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១២៧៦ .អនក្រ.តត

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសុវត្ថារា ថ្នាក់ សេនា ជូនលោក ស៊ិន សុឃន ប្រធានមជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ជូនជាតិមាតុភូមិ ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧៣៧ . អនក្រ .បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ ជូនមន្ត្រីរាជការ ចំនួន០២រូប នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម ៖

១-លោក អ៊ុយ នារត្ន អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

២-លោក ស៊ីន សុភីន អនុប្រធាននាយកដ្ឋានក្របខ័ណ្ឌសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១០
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៣៥ . អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន២៣រូប នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ:

១-លោក	គឹម	ឌីណា	អធិការ
២-លោក	ឈិត្យ	ថន្យ	អនុប្រធាននាយកដ្ឋាននីតិកម្ម និងវិវាទមុខងារសាធារណៈ
៣-លោក	សឹក	ហេងឡុង	អនុប្រធានមជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា
៤-លោក	ម៉េង	ម៉ង់និត	អនុប្រធានមជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា

ខ-មេដាយប្រាក់ការងារ:

១-លោក	ជ័យ	ភុយ	ប្រធានការិយាល័យឯកសារ
២-លោក	ឈិន	សុគីភ	អនុប្រធាននាយកដ្ឋានត្រួតពិនិត្យរដ្ឋបាល
៣-លោកស្រី	ម៉ាស	សុគន្ធា	អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
៤-លោក	ទ៉េង	លាភ	ប្រធានការិយាល័យ
៥-លោក	ឈុន	ពិសិដ្ឋ	អនុប្រធានការិយាល័យ

គ-មេដាយសិរីវឌ្ឍនភាព:

១-លោក	លី	ហេង	ប្រធានការិយាល័យ
២-លោក	គង់	សុវត្ថិភាព	អនុប្រធានការិយាល័យ
៣-លោក	វិសិដ្ឋ	សារ៉េត្ន	អនុប្រធានការិយាល័យ
៤-លោក	ស៊ុក	សុវណ្ណដា	អនុប្រធានការិយាល័យ
៥-លោកស្រី	ស្រួន	ចរិយា	អនុប្រធានការិយាល័យ
៦-លោកស្រី	ឈុំប	សុធាន	អនុប្រធានការិយាល័យ
៧-លោក	ស៊ីន	សុខឃៀង	អនុប្រធានការិយាល័យ
៨-លោក	ហ៊ីន	ពិសី	អនុប្រធានការិយាល័យ
៩-លោក	សុត	សារ៉ា	មន្ត្រី
១០-លោក	ជៀប	រ៉ា	មន្ត្រី
១១-លោកស្រី	ហ៊ុត	សុគន្ធា	មន្ត្រី
១២-លោក	ស	គ្រាន់	មន្ត្រី
១៣-លោក	តាត	ចាន់សាត	មន្ត្រី
១៤-លោក	រី	សិទ្ធី	មន្ត្រី

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧៣៩ . អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន២៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមក្នុងការកសាងសាលាហោត្រៃ និងសមិទ្ធផលផ្សេងៗមួយចំនួនទៀត រួមចំណែកក្នុងការអភិវឌ្ឍព្រះពុទ្ធសាសនា នៅវត្តពោធិព្រះពន្លា ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិ:

១-ព្រះតេជគុណ គួយ ម៉ែត ព្រះគ្រូចៅអធិការវត្ត បច្ច័យចំនួន ១៨.៥០០ ដុល្លារ
២-ឧបាសក សំ រិន ថវិកាចំនួន ១៥.៣០០ ដុល្លារ
៣-ឧបាសិកា ហេង ខេង ថវិកាចំនួន ១២.០០០ ដុល្លារ
៤-អ្នកស្រី ឈ័ក្ង លីស៊ីណា ថវិកាចំនួន ៥៥.៨៣៦ ដុល្លារ
៥-លោក ជួង ស្រួច ថវិកាចំនួន ១២.៥០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ:

១-ឧបាសិកា ម៉ែន ឈៀម ថវិកាចំនួន ៥.៥០០ ដុល្លារ
២-លោក ម៉ែន យុត ថវិកាចំនួន ៥.៣៥០ ដុល្លារ
៣-អ្នកស្រី រិន ទៃ ថវិកាចំនួន ៥.៣០០ ដុល្លារ
៤-អ្នកស្រី សុខ សុខេន ថវិកាចំនួន ៥.២៥០ ដុល្លារ

គ-មេដាយសិរីវឌ្ឍនស្ថាបនាជាតិ :

១-លោក	ហាក់ ទីទ្រី	ថវិកាចំនួន	២.៧០០	ដុល្លារ
២-ឧបាសក	សួន ប៊ូន	ថវិកាចំនួន	២.៣២០	ដុល្លារ
៣-លោក	ឆា ម៉ូឃៀង	ថវិកាចំនួន	១.៨០០	ដុល្លារ
៤-លោក	ផាន សុផាត់	ថវិកាចំនួន	១.៦០០	ដុល្លារ
៥-ឧបាសិកា	ឆន់ គី	ថវិកាចំនួន	១.៥០០	ដុល្លារ
៦-លោក	ឈឹម ឈួន	ថវិកាចំនួន	១.៤៥០	ដុល្លារ
៧-លោក	ខុិ ឈិន	ថវិកាចំនួន	១.៤៥០	ដុល្លារ
៨-លោក	អ៊ុក សុទ្ធ	ថវិកាចំនួន	១.៤០០	ដុល្លារ
៩-លោក	សេក មឿន	ថវិកាចំនួន	១.៤០០	ដុល្លារ
១០-លោក	ទិន ឆោម	ថវិកាចំនួន	១.៣៥០	ដុល្លារ
១១-លោក	ម៉ែម គង់	ថវិកាចំនួន	១.៣៥០	ដុល្លារ
១២-លោក	ថាន ឃួន	ថវិកាចំនួន	១.៣០០	ដុល្លារ
១៣-លោក	ម៉ី សាគីម	ថវិកាចំនួន	១.៣០០	ដុល្លារ
១៤-លោក	ឆយ អាន	ថវិកាចំនួន	១.២៥០	ដុល្លារ
១៥-លោក	តូប ឌុច	ថវិកាចំនួន	១.១៥០	ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១២៤០.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរភារកិច្ចនិងតែងតាំងមុខតំណែងនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកស្រីឧត្តមសេនីយ៍ទោ **អ៊ុន សុគន្ធា** អត្តលេខ ០២៥៩ ពីអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ទៅជាអគ្គស្នងការរងនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ៩ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៤១ ឯ.ក្រ.ចក

អនុក្រឹត្យ

ស្តីពី

ការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល

សម្រេច

មាត្រា ១ ៖ ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងសប្បុរសជនចំនួន ៥៤ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយក្នុងកិច្ចកសាង អភិវឌ្ឍន៍នូវសមិទ្ធផលនានា ស្ថិតក្នុងស្រុកលើកដែក ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ៖

១-លោក	វ៉ៃ	ធឿន	អនុប្រធាននាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ
២-លោក	ស៊ូ	ម៉ិនធឿន	អនុប្រធាននាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ
៣-លោក	សុខ	សុផាន	អនុប្រធាននាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ
៤-លោក	ឆ្អិ	ចាន់កុសល	អនុប្រធាននាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ
៥-លោក	ស	សារ៉ាន	ស្នងការរងនគរបាលខេត្តកោះកុង
៦-លោក	អ៊ាន	សុភ័ក្ត្រ	ជំនួយការអគ្គនាយករងភស្តុភារនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ
៧-លោក	ឌឿម	សាម៉ុន	នាយរងការិយាល័យ អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ
៨-លោក	ហាស់	ឌីណា	ជំនួយការអគ្គនាយករងភស្តុភារនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ
៩-លោក	ហាច	តិរៈមៀ	នាយផ្នែក អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ
១០-លោក	លឹម	សាធឿន	នាយផ្នែក អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ

១១-លោក ឃុ សុណារី នាយការិយាល័យផែនការគណនេយ្យ ស្នងការដ្ឋាននគរបាលខេត្តក្រចេះ
១២-លោក ឃាង ខ៊ាន់ឡើន នាយផ្នែក នាយកដ្ឋានផែនការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
១៣-លោក ទ្បើន សារ៉ាត់ នាយផ្នែកប្រេងឥន្ធនៈ នាយកដ្ឋានភស្តុភារនិងសំភារបច្ចេកទេស
១៤-លោក ពូ ពុទ្ធី នាយផ្នែក អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ
១៥-លោក ស៊ឹម ហុងហួត មន្ត្រីនគរបាលជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ
១៦-លោក អ៊ុក ដារ៉ា នាយរងផ្នែក អគ្គស្នងការដ្ឋាននគរបាលជាតិ
១៧-លោក ហាក់ សិរីរតនៈ នាយរងផ្នែក ការិយាល័យលិខិតឆ្លងដែន នាយកដ្ឋានអន្តោប្រវេសន៍
១៨-លោក សាត សោភ័ណ្ឌា មន្ត្រីនគរបាល នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ
១៩-លោក ឡឹក សុខា នាយរងការិយាល័យការពារខេត្តក្រុង នាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ
២០-លោក ឈិន គីរិន មន្ត្រីនគរបាល នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ
២១-លោក អ៊ិន សម្ល័ស្ស មន្ត្រីនគរបាលជាតិ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ
២២-លោក ឈឹម នឹម មេបញ្ជាការវរៈនគរបាលការពារព្រំដែនលេខ៨២៧ ខេត្តកោះកុង
២៣-លោក តូច ចណ្ណារិទ្ធ អធិការនគរបាលស្រុកគិរីសាគរ ស្នងការដ្ឋាននគរបាលខេត្តកោះកុង
២៤-លោក ជា សុចណ្ណតារិត នាយរងផ្នែក ការិយាល័យបុគ្គលិក ស្នងការដ្ឋាននគរបាលខេត្តកោះកុង
២៥-លោក ស៊ិន សុឿន នាយប៉ុស្តិ៍អណ្តូងខ្មែរ ស្នងការដ្ឋាននគរបាលខេត្តកំពត
២៦-លោក ជា ជាង នាយរងការិយាល័យចរាចរណ៍ផ្លូវទឹក ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម
២៧-លោក អែម ពៅជ្រ នាយរងការិយាល័យសណ្តាប់ធ្នាប់ ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម
២៨-លោក ឡាយ ឌួន អធិការនគរបាលស្រុកក្រូចឆ្មារ ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម
២៩-លោក ជា ហេង នាយផ្នែកបៀវត្សរ៍ ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម
៣០-លោក ផាង ទីរៈ មន្ត្រីនគរបាលជាតិ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
៣១-លោក ផាង សុតារុណា មន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្ស ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
៣២-លោក ផាង សុខតារស្មី មន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្ស ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
៣៣-លោក អ៊ិន សំអាត មន្ត្រីនគរបាលជាតិ អធិការដ្ឋាននគរបាលខណ្ឌ៧មករា
៣៤-លោក សន ពិសី មន្ត្រីការិយាល័យព្រហ្មទណ្ឌកិតស្រាល ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
៣៥-លោក អ៊ាន់ សាវ៉េត មន្ត្រីនគរបាលជាតិ អធិការដ្ឋាននគរបាលខណ្ឌ៧មករា
៣៦-លោក ស៊ិន សារិទ្ធ នាយរងការិយាល័យការពារខេត្តក្រុង នៃនាយកដ្ឋានការពារបេតិកភណ្ឌ
៣៧-លោក អ៊ូ ចន្ថា មន្ត្រីនគរបាលជាតិ នៃអធិការដ្ឋាននគរបាលខណ្ឌដង្កោ
៣៨-លោក ឆាំ វណ្ណារ៉ា នាយរងផ្នែក នាយកដ្ឋានព្រហ្មទណ្ឌ ក្រសួងមហាផ្ទៃ
៣៩-លោក សឿន វុធចាន់ណាវី មន្ត្រីនគរបាលជាតិ នាយកដ្ឋានព្រហ្មទណ្ឌ
៤០-លោក គួរ ចិន្តា មន្ត្រីនគរបាលជាតិ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប
៤១-លោក ថា សុជាតិ នាយរងផ្នែក អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ

៤២-លោក	ស៊ុំ	ម៉េន	នាយរងផ្នែក អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ
៤៣-លោក	ឈឹម	ចាន់ពិសិដ្ឋ	មន្ត្រីនគរបាលជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ
៤៤-លោក	ទូច	សុធារៈ	មន្ត្រីនគរបាលជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ
៤៥-លោក	ហ៊ាច	តារា	មន្ត្រីនគរបាលជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ
៤៦-លោក	អ៊ុក	ដារ៉ាន់	មន្ត្រីនគរបាលជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ
៤៧-លោក	ដា	ពៅ	មន្ត្រីនគរបាលជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ
៤៨-លោក	ដន	ស៊ាខហ៊ែ	មន្ត្រីនគរបាលជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ
៤៩-លោក	ច័ន្ទ	ណារ៉ាសីហ៍	មន្ត្រីនគរបាលជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ
៥០-លោក	នៅ	ចំរើន	មន្ត្រីនគរបាលជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ
៥១-លោក	គូ	ដាណេ	នាយផ្នែក សេនាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ
៥២-លោក	នៅ	ចំណាន	នាយផ្នែក សេនាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ
៥៣-លោក	អឿ	ចាន់ធីឿងឿខ	នាយផ្នែកភស្តុភារ វរៈនគរបាលការពារព្រំដែនគោកខេត្តកោះកុង
៥៤-លោក	ឡាច	ឃួម	មន្ត្រីនគរបាលជាតិ ក្រសួងមហាផ្ទៃ

មាត្រា ២ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល នៃគណៈអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ៕

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៤៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យ លេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យ លេខ ០៥ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សម្រេច

មាត្រា ១ : តែងតាំងលោក **ឡាយ ម៉ារីទ៉ូ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៨៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១: ត្រូវបានផ្ទេរភារកិច្ច លោកស្រី **ចឹក ជីវី** ពីអធិការ នៃអធិការដ្ឋានអប់រំ ទៅជាប្រធាននាយកដ្ឋានធានាគុណភាពអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២: ប្រគល់ភារកិច្ចជូន លោក **ចាប សោភ័ណ** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ នៃក្រសួងអប់រំ យុវជន និងកីឡា ជំនួសលោក **យ៉ង យ៉ាណា** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

មាត្រា ៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ជូចមានចែងក្នុងមាត្រា ១ និង ២ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០៧៦...សហវ.ទកដ

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០

សេចក្តីសម្រេច

ស្តីពី

ការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ រាជធានីភ្នំពេញ

ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨.១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៩៨_អនក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសម្រេចលេខ ០០៤ សសរ.សហវ.ពដ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ០៦៧ សហវ.ប្រក.ពដ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៩ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញសំណើលេខ ១៦៩ សស.ហិរ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១០ របស់សាលារាជធានីភ្នំពេញ ស្តីពីការកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅរាជធានីភ្នំពេញ ។

សម្រេច

ប្រការ ១.- បង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម :

១.	លោកស្រី ឡូច សារ៉ុម	អភិបាលរងរាជធានីភ្នំពេញ	ប្រធាន
២.	លោក អោម ចន	អនុប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ	អនុប្រធានប្រចាំការ
៣.	លោក ឈី សារ៉េត	នាយករដ្ឋបាលសាលារាជធានីភ្នំពេញ	អនុប្រធាន
៤.	លោក ឆាយ ឫទ្ធិសែន	ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ	អនុប្រធាន
៥.	លោក គើត ឆែ	នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ	សមាជិក
៦.	លោក ម៉ែត មង្គាទី	ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ	សមាជិក
៧.	លោក ផេង សុខាំ	ប្រធានមន្ទីរកសិកម្ម រាជធានីភ្នំពេញ	សមាជិក
៨.	លោកស្រី មុំ សុណ្ណាប់	ប្រធានមន្ទីរផែនការរាជធានីភ្នំពេញ	សមាជិក
៩.	លោក ប៊ុន សើរី	នាយកទីចាត់ការហិរញ្ញវត្ថុសាលារាជធានីភ្នំពេញ	សមាជិក
១០.	លោក ទឹម គុណា	ប្រធានការិយាល័យស្ថិតិ និងប្រថាប់ត្រា នៃនាយកដ្ឋាន ច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ	សមាជិក
១១.	លោក ស៊ិន មុណីមី	នាយកទីចាត់ការរៀបចំក្រុង	សមាជិក
១២.	លោក ម៉ិត សារ៉េត	ប្រធានការិយាល័យហិរញ្ញកិច្ច	សមាជិក
១៣.	លោក ថាល ធីរ៉េត	អនុប្រធានការិយាល័យស្ថិតិ និងប្រថាប់ត្រា នៃនាយកដ្ឋាន ច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ	សមាជិក
១៤.	លោក គីម គន្ធារី	អនុប្រធានការិយាល័យស្ថិតិ និងប្រថាប់ត្រា នៃនាយកដ្ឋាន ច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ	សមាជិក
១៥.	លោក ហោ ទ៉ាន់ហ៊ីម	អនុប្រធានការិយាល័យស្ថិតិ និងប្រថាប់ត្រា នៃនាយកដ្ឋាន ច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ	សមាជិក

ប្រការ ២.- អនុគណៈកម្មការមានភារកិច្ច ៖

- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងរាជធានីភ្នំពេញ
- លើកគម្រោងតម្លៃដីក្នុងមួយម៉ែត្រក្រឡា គិតតាមតំបន់នីមួយៗក្នុងរាជធានីភ្នំពេញ ដើម្បីជាមូលដ្ឋានគណនាប្រាក់ពន្ធដាក់ជូនគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ពិនិត្យ និងសម្រេច
- ផ្តល់មតិចំពោះរឿងវិវាទនានា ដែលពាក់ព័ន្ធទៅនឹងដីមិនបានប្រើប្រាស់ ។

ប្រការ ៣.- អនុគណៈកម្មការអាចរៀបចំបង្កើតក្រុមជំនួយការមួយ ដើម្បីធានានិរន្តរភាពក្នុងប្រតិបត្តិការរបស់អនុគណៈកម្មការ ។

ប្រការ ៤.- សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ ។

ប្រការ ៥.- អនុគណៈកម្មការត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការ និងត្រូវរាយការណ៍ជាប្រចាំតាមខែនីមួយៗ មកគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ៦.- សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧.- ឯកឧត្តម លោក-លោកស្រី ដូចមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

គាត់ ចំប៉ុល

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- សាលារាជធានីភ្នំពេញ *"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- ដូចប្រការ៧ *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០៣៧...សហវ. សអ.ឃ

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០

សេចក្តីសម្រេច

ស្តីពី

ការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

ខេត្តកំពង់ស្ពឺ

ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨.១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៥៨ អនក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសម្រេចលេខ ០០៤ សសរ.សហវ.ពដ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ០៦៧ សហវ.ប្រក.ពដ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៩ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញសំណើលេខ ២៨១ អបខ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១០ របស់សាលាខេត្តកំពង់ស្ពឺ ស្តីពីការកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅខេត្តកំពង់ស្ពឺ ។

សម្រេច

ប្រការ ១.- បង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅខេត្តកំពង់ស្ពឺ ដែលមានសមាសភាព ដូចខាងក្រោម :

១. ឯកឧត្តម	នុច សេច	អភិបាលរងខេត្ត	ប្រធាន
២. លោក	ឡាយ គីមហ៊ាង	ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត	អនុប្រធាន
៣. លោក	ឌឹម ម៉េត	ប្រធានសាខាពន្ធដារខេត្ត	អនុប្រធានប្រចាំការ
៤. លោក	សេង សៀង	អនុប្រធានមន្ទីរកសិកម្មខេត្ត	សមាជិក
៥. លោក	ចិន ម៉ុនថា	អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត	សមាជិក

ប្រការ ២.- អនុគណៈកម្មការមានភារកិច្ច :

- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងខេត្ត
- លើកគម្រោងតម្លៃដីក្នុងមួយម៉ែត្រក្រឡា គិតតាមតំបន់នីមួយៗក្នុងខេត្ត ដើម្បីជាមូលដ្ឋានគណនាប្រាក់ពន្ធដាក់ជូនគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ពិនិត្យ និងសម្រេច
- ផ្តល់មតិចំពោះរឿងវិវាទនានា ដែលពាក់ព័ន្ធទៅនឹងដីមិនបានប្រើប្រាស់ ។

ប្រការ ៣.- អនុគណៈកម្មការអាចរៀបចំបង្កើតក្រុមជំនួយការមួយ ដើម្បីធានានិរន្តរភាពក្នុងប្រតិបត្តិការរបស់អនុគណៈកម្មការ ។

ប្រការ ៤.- សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ ។

ប្រការ ៥.- អនុគណៈកម្មការត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការ និងត្រូវរាយការណ៍ជាប្រចាំតាមខែនីមួយៗ មកគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ៦.- សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧.- ឯកឧត្តម លោក-លោកស្រី ដូចមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

គាត់ ចំបុល

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

__កន្លែងទទួល__ :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នកណ្តាល
- សាលាខេត្តកំពង់ស្ពឺ *"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- ដូចប្រការ៧ *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៣៥ សហវ. [illegible]

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០

សេចក្តីសម្រេច
ស្តីពី
ការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
ខេត្តប៉ៃលិន

ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨.១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៥៨ អនក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសម្រេចលេខ ០០៤ សសរ.សហវ.ពដ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ០៦៧ សហវ.ប្រក.ពដ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៩ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញសំណើលេខ ៦៥៣ លស.បល ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ របស់សាលាខេត្តប៉ៃលិន ស្តីពីការស្នើសុំកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅខេត្តប៉ៃលិន ។

សម្រេច

ប្រការ ១.- បង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅខេត្តប៉ៃលិន ដែលមានសមាសភាព ដូចខាងក្រោម ៖

១.	ឯកឧត្តម សឿន ឌុន	អភិបាលរងនៃគណៈអភិបាលខេត្ត	ប្រធាន
២.	លោក ម៉ុក សុផល	ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត	អនុប្រធាន
៣.	លោក អ៊ុក សារិន	ប្រធានសាខាពន្ធដារខេត្ត	អនុប្រធានប្រចាំការ
៤.	លោក រាម សុមាន	ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត	សមាជិក
៥.	លោក ផាន់ ពៅ	ប្រធានមន្ទីរកសិកម្មខេត្ត	សមាជិក
៦.	លោក យឹម ឡាំង	អភិបាលនៃគណៈអភិបាលស្រុកសាលាក្រៅ	សមាជិក
៧.	លោក សួស ស៊ីយ៉ាន	អភិបាលនៃគណៈអភិបាលក្រុងប៉ៃលិន	សមាជិក
៨.	លោក រស់ ឡឿន	នាយទីចាត់ការអន្តរវិស័យខេត្ត	សមាជិក

ប្រការ ២.- អនុគណៈកម្មការមានភារកិច្ច ៖

- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងខេត្ត
- លើកគម្រោងតម្លៃដីក្នុងមួយម៉ែត្រក្រឡា គិតតាមតំបន់នីមួយៗក្នុងខេត្ត ដើម្បីជាមូលដ្ឋានគណនាប្រាក់ពន្ធដាក់ជូនគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ពិនិត្យ និងសម្រេច
- ផ្តល់មតិចំពោះរឿងវិវាទនានា ដែលពាក់ព័ន្ធទៅនឹងដីមិនបានប្រើប្រាស់ ។

ប្រការ ៣.- អនុគណៈកម្មការអាចរៀបចំបង្កើតក្រុមជំនួយការមួយ ដើម្បីធានានិរន្តរភាពក្នុងប្រតិបត្តិការរបស់អនុគណៈកម្មការ ។

ប្រការ ៤.- សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ ។

ប្រការ ៥.- អនុគណៈកម្មការត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការ និងត្រូវរាយការណ៍ជាប្រចាំតាមខែនីមួយៗ មកគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ៦.- សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧.- ឯកឧត្តម លោក-លោកស្រី ដូចមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

គង់ វិបុល

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នកណ្តាល
- សាលាខេត្តប៉ៃលិន *"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- ដូចប្រការ៧ *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០៧៩.....សហវ.ស្រាវ

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០

សេចក្តីសម្រេច
ស្តីពី
ការបង្កើតអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យនៅរាជធានីភ្នំពេញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ
- បានឃើញប្រកាសលេខ ៤៩៤ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធ លើអចលនទ្រព្យ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើអចលនទ្រព្យនៅរាជធានីភ្នំពេញ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

សម្រេច

ប្រការ ១.-

បង្កើតអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ នៅរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម :

១. លោកស្រី	នួន សារ៉ុម	អភិបាលរងរាជធានីភ្នំពេញ	ប្រធាន
២. លោក	អោម ចន	អនុប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ	អនុប្រធានប្រចាំការ
៣. លោក	លី សារេធ	នាយករដ្ឋបាលសាលារាជធានីភ្នំពេញ	អនុប្រធាន
៤. លោក	ឆាយ ឫទ្ធីសែន	ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ	អនុប្រធាន
៥. លោក	កើត ឆែ	នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ	សមាជិក
៦. លោក	ខ័ត ចន្ថារី	ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ	សមាជិក
៧. លោក	ដេង សុខា	ប្រធានមន្ទីរកសិកម្ម រាជធានីភ្នំពេញ	សមាជិក
៨. លោកស្រី	ម៉ុំ សណ្តាប់	ប្រធានមន្ទីរផែនការរាជធានីភ្នំពេញ	សមាជិក
៩. លោក	ម៉ុន សេរី	នាយកទីចាត់ការហិរញ្ញវត្ថុសាលារាជធានីភ្នំពេញ	សមាជិក
១០. លោក	អ៊ឹម តុលា	ប្រធានការិយាល័យស្ថិតិ និងប្រថាប់ត្រា នៃនាយកដ្ឋាន ច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ	សមាជិក
១១. លោក	ស៊ិន បុណ្ណរិទ្ធិ	នាយកទីចាត់ការរៀបចំក្រុង	សមាជិក
១២. លោក	ម៉ុត សារ៉េត	ប្រធានការិយាល័យហិរញ្ញកិច្ច	សមាជិក
១៣. លោក	ហ៊ល ធីរិត	អនុប្រធានការិយាល័យស្ថិតិ និងប្រថាប់ត្រា នៃនាយកដ្ឋាន ច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ	សមាជិក
១៤. លោក	គឹម គន្ធារី	អនុប្រធានការិយាល័យស្ថិតិ និងប្រថាប់ត្រា នៃនាយកដ្ឋាន ច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ	សមាជិក
១៥. លោក	ហោ ម៉ាន់ហ៊ឹម	អនុប្រធានការិយាល័យស្ថិតិ និងប្រថាប់ត្រា នៃនាយកដ្ឋាន ច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ	សមាជិក

ប្រការ ២.-

អនុគណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

- រៀបចំបញ្ជីសរុបអចលនទ្រព្យ និងរៀបចំតម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់ នៅតាមមូលដ្ឋាន ក្នុងដែនសមត្ថកិច្ចរាជធានី និងបញ្ជូនមកគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ផ្សព្វផ្សាយ ណែនាំ និងអប់រំក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ ព្រមទាំងអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយជាសាធារណៈរួមទាំងបិទប្រកាសផ្សាយនៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចរាជធានី
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- សម្របសម្រួល និងសហការជាមួយរដ្ឋបាលសារពើពន្ធក្នុងកិច្ចដំណើរការអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ
- តាមដាន ត្រួតពិនិត្យ រំលឹក ជំរុញការអនុវត្តរបស់ក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់
- សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ
- ក្នុងករណីចាំបាច់ អនុគណៈកម្មការនេះមានសិទ្ធិបង្កើតក្រុមការងារជាជំនួយការផ្ទាល់បន្ថែមទៀត នៅថ្នាក់ក្រុង-ស្រុក-ខណ្ឌ ដើម្បីធ្វើការសម្របសម្រួលក្រុមការងារថ្នាក់ឃុំ-សង្កាត់ ក្នុងការអនុវត្តភារកិច្ចខាងលើ ។

ប្រការ ៣.-

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យរាជធានីមានសិទ្ធិបង្កើតក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ ជាជំនួយការក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមការងារនេះមានភារកិច្ចដូចតទៅ :

- រួមសហការផ្សព្វផ្សាយ ណែនាំ និងអប់រំអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- សហការជាមួយរដ្ឋបាលសារពើពន្ធ ដើម្បីរៀបចំបញ្ជីលម្អិតអចលនទ្រព្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយបញ្ជូនមកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យរាជធានី
- ចូលរួមកំណត់អចលនទ្រព្យតាមតំបន់ ប្រភេទ និងទីតាំង ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមសេចក្តីណែនាំរបស់គណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ចូលរួមផ្សព្វផ្សាយ រួមទាំងបិទប្រកាសផ្សាយតម្លៃអចលនទ្រព្យ នៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ជួយសហការផ្តល់ស្ថិតិ និងទិន្នន័យសម្រាប់ការចុះបញ្ជីអចលនទ្រព្យដល់រដ្ឋបាលសារពើពន្ធ

- ជួយសហការការងារដទៃទៀតជាមួយរដ្ឋបាលសារពើពន្ធតាមការស្នើសុំ
- សមាជិកក្រុមការងារ ត្រូវចូលរួមធ្វើការ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានក្រុមការងារ ។

ប្រការ ៤.-

សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥.-

ឯកឧត្តម លោក-លោកស្រី ដែលជាសមាសភាពដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រធានគណៈកម្មការវាយតម្លៃអចលនទ្រព្យ

ភ្នាក់ងារវាយតម្លៃអចលនទ្រព្យ

គង់ វិបុល

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នកណ្តាល
- សាលារាជធានីភ្នំពេញ

  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ៤ *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៤០ សហវ. សអវ

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០

សេចក្តីសម្រេច
ស្តីពី
ការបង្កើតអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យខេត្តកំពង់ស្ពឺ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ
- បានឃើញប្រកាសលេខ ៤៩៤ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធ លើអចលនទ្រព្យ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើអចលនទ្រព្យខេត្តកំពង់ស្ពឺ

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥ ២៣ ៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

សម្រេច

ប្រការ ១.-

បង្កើតអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ ខេត្តកំពង់ស្ពឺដែលមានសមាសភាពដូចខាងក្រោម :

១. ឯកឧត្តម	គុង សេង	អភិបាលរងខេត្ត	ប្រធាន
២. លោក	ឡាយ គឹមហ៊ាង	ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត	អនុប្រធាន
៣. លោក	ធីម ផេត	ប្រធានសាខាពន្ធដារខេត្ត	អនុប្រធានប្រចាំការ
៤. លោក	សេង សៀង	អនុប្រធានមន្ទីរកសិកម្មខេត្ត	សមាជិក
៥. លោក	ថន ប៊ុនថា	អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត	សមាជិក

ប្រការ ២.-

អនុគណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

- រៀបចំបញ្ជីសរុបអចលនទ្រព្យ និងរៀបចំតម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់នៅតាមមូលដ្ឋាន ក្នុងដែនសមត្ថកិច្ចខេត្ត និងបញ្ជូនមកគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ផ្សព្វផ្សាយ ណែនាំ និងអប់រំក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ ព្រមទាំងអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយជាសាធារណៈ រួមទាំងបិទប្រកាសផ្សាយនៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចខេត្ត
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- សម្របសម្រួល និងសហការជាមួយរដ្ឋបាលសារពើពន្ធក្នុងកិច្ចដំណើរការអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ
- តាមដាន ត្រួតពិនិត្យ រំលឹក ជំរុញការអនុវត្តរបស់ក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់
- សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ
- ក្នុងករណីចាំបាច់ អនុគណៈកម្មការនេះអាចបង្កើតក្រុមការងារជាជំនួយការផ្ទាល់បន្ថែមទៀតនៅថ្នាក់ក្រុង-ស្រុក-ខណ្ឌ សម្រាប់ធ្វើការសម្របសម្រួលក្រុមការងារថ្នាក់ឃុំ-សង្កាត់ ។

ប្រការ ៣.-

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យខេត្ត មានសិទ្ធិបង្កើតក្រុមការងារអចលនទ្រព្យ ឃុំ-សង្កាត់ជាជំនួយការក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម ៖

- រួមសហការផ្សព្វផ្សាយ ណែនាំ និងអប់រំអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានាស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- សហការជាមួយរដ្ឋបាលសារពើពន្ធ ដើម្បីរៀបចំបញ្ជីលម្អិតអចលនទ្រព្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយបញ្ជូនមកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យខេត្ត
- ចូលរួមកំណត់អចលនទ្រព្យតាមតំបន់ ប្រភេទ និងទីតាំង ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមសេចក្តីណែនាំរបស់គណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ចូលរួមផ្សព្វផ្សាយ រួមទាំងបិទប្រកាសផ្សាយតម្លៃអចលនទ្រព្យ នៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ជួយសហការផ្តល់ស្ថិតិ និងទិន្នន័យសម្រាប់ការចុះបញ្ជីអចលនទ្រព្យដល់រដ្ឋបាលសារពើពន្ធ
- ជួយសហការការងារផ្សេងទៀតជាមួយរដ្ឋបាលសារពើពន្ធតាមការស្នើសុំ
- សមាជិកក្រុមការងារ ត្រូវចូលរួមធ្វើការ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានក្រុមការងារ ។

ប្រការ ៤.-

សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥.-

ឯកឧត្តម លោក-លោកស្រី ដែលជាសមាសភាពដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រធានគណៈកម្មការវាយតម្លៃអចលនទ្រព្យ
ប្រមូលពន្ធលើអចលនទ្រព្យ

គង់ វិបុល

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នកណ្តាល
- សាលាខេត្តកំពង់ស្ពឺ

  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ៤ *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០៤១.....សហវ.អកហ

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ ៨ ឆ្នាំ ២០១០

សេចក្តីសម្រេច
ស្តីពី
ការបង្កើតអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យខេត្តប៉ៃលិន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ
- បានឃើញប្រកាសលេខ ៤៩៤ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធ លើអចលនទ្រព្យ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើអចលនទ្រព្យខេត្តប៉ៃលិន

សម្រេច

ប្រការ ១.-

បង្កើតអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ ខេត្តប៉ៃលិនដែលមានសមាសភាពដូចខាងក្រោម :

១. ឯកឧត្តម អឿន នុន	អភិបាលរងនៃគណៈអភិបាលខេត្ត	ប្រធាន
២. លោក ហុក សុផល	ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត	អនុប្រធាន
៣. លោក អ៊ុក សារិន	ប្រធានសាខាពន្ធដារខេត្ត	អនុប្រធានប្រចាំការ
៤. លោក រាម សុមាន	ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត	សមាជិក
៥. លោក ផាន់ ពេជ្រ	ប្រធានមន្ទីរកសិកម្មខេត្ត	សមាជិក
៦. លោក យឹម ឡារិន	អភិបាលនៃគណៈអភិបាលស្រុកសាលាក្រៅ	សមាជិក
៧. លោក សួស ស៊ីយ៉ាត	អភិបាលនៃគណៈអភិបាលក្រុងប៉ៃលិន	សមាជិក
៨. លោក រស់ នឿន	នាយទីចាត់ការអន្តរវិស័យខេត្ត	សមាជិក

ប្រការ ២.-

អនុគណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

- រៀបចំបញ្ជីសរុបអចលនទ្រព្យ និងរៀបចំតម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់នៅតាមមូលដ្ឋាន ក្នុងដែនសមត្ថកិច្ចខេត្ត និងបញ្ជូនមកគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ផ្សព្វផ្សាយ ណែនាំ និងអប់រំក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ ព្រមទាំងអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយជាសាធារណៈ រួមទាំងបិទប្រកាសផ្សាយនៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចខេត្ត
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- សម្របសម្រួល និងសហការជាមួយរដ្ឋបាលសារពើពន្ធក្នុងកិច្ចដំណើរការអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ
- តាមដាន ត្រួតពិនិត្យ រំលឹក ជំរុញការអនុវត្តរបស់ក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់
- សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ
- ក្នុងករណីចាំបាច់ អនុគណៈកម្មការនេះអាចបង្កើតក្រុមការងារជាជំនួយការផ្ទាល់បន្ថែមទៀតនៅថ្នាក់ក្រុង-ស្រុក-ខណ្ឌ សម្រាប់ធ្វើការសម្របសម្រួលក្រុមការងារថ្នាក់ឃុំ-សង្កាត់ ។

ប្រការ ៣.-

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យខេត្ត មានសិទ្ធិបង្កើតក្រុមការងារអចលនទ្រព្យ ឃុំ-សង្កាត់ ជាជំនួយការក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម :

- រួមសហការផ្សព្វផ្សាយ ណែនាំ និងអប់រំអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានាស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- សហការជាមួយរដ្ឋបាលសារពើពន្ធ ដើម្បីរៀបចំបញ្ជីលម្អិតអចលនទ្រព្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយបញ្ជូនមកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យខេត្ត
- ចូលរួមកំណត់អចលនទ្រព្យតាមតំបន់ ប្រភេទ និងទីតាំង ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមសេចក្តីណែនាំរបស់គណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ចូលរួមផ្សព្វផ្សាយ រួមទាំងបិទប្រកាសផ្សាយតម្លៃអចលនទ្រព្យ នៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ជួយសហការផ្តល់ស្ថិតិ និងទិន្នន័យសម្រាប់ការចុះបញ្ជីអចលនទ្រព្យដល់រដ្ឋបាលសារពើពន្ធ
- ជួយសហការការងារផ្សេងទៀតជាមួយរដ្ឋបាលសារពើពន្ធតាមការស្នើសុំ
- សមាជិកក្រុមការងារ ត្រូវចូលរួមធ្វើការ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានក្រុមការងារ ។

ប្រការ ៤.-

សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥.-

ឯកឧត្តម លោក-លោកស្រី ដែលជាសមាសភាពដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រធានគណៈកម្មការវាយតម្លៃអចលនទ្រព្យ
សម្រាប់ពន្ធលើអចលនទ្រព្យ

គាត ឈន់
រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នកណ្តាល
- សាលាខេត្តប៉ៃលិន

  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ចម្លងត្រឹមត្រូវ
ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧ ១២-០៩-២១៩ ប្រក

ប្រកាស

ស្តីពី

រចនាសម្ព័ន្ធ មុខងារ និងភារកិច្ចរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៨ ស្តីពីការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្រ.តត ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- យោងតាមស្មារតីនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លើកទី ៤ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩

ស ម្រេ ច

ប្រការ ១.- រៀបចំរចនាសម្ព័ន្ធ និង កំណត់មុខងារនិងភារកិច្ចរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ហៅកាត់ថា "**ស.ហ.ក**" និង ការិយាល័យ និង ផ្នែកក្រោមឱវាទនៅក្នុងប្រការបន្តបន្ទាប់ខាងក្រោម ។

ប្រការ ២. ស.ហ.ក មានមុខងារ និង ភារកិច្ចចំបងៗគឺ ÷

ក- ទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ ប្រតិបត្តិការសាច់ប្រាក់ និងព័ត៌មានស្តីពីការសង្ស័យនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ខ- ប្រមូលព័ត៌មានដែល ស.ហ.ក យល់ថាទាក់ទងនឹងសកម្មភាពរបស់ខ្លួន ស្តីពីការសម្អាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្ម ហើយដែលមានផ្សព្វផ្សាយជាសាធារណៈ រួមមាន ទិន្នន័យពាណិជ្ជកម្ម ក៏ដូចជាព័ត៌មានផ្សេងៗ ទៀតដែលចាំបាច់សម្រាប់អនុវត្តមុខងាររបស់ខ្លួន ដូចជា ព័ត៌មានដែលបានប្រមូល និងរក្សាទុកក្នុងទិន្នន័យដោយបុគ្គលរាយការណ៍

គ- យកតាមកាលានុវត្តស្របតាមច្បាប់នូវព័ត៌មានហិរញ្ញវត្ថុ រដ្ឋបាល និង ព័ត៌មានសម្រាប់ការពង្រឹងការអនុវត្តន៍ច្បាប់ ដែលចាំបាច់សម្រាប់ការបំពេញមុខងាររបស់ខ្លួន រួមទាំងព័ត៌មានដែលត្រូវបានប្រមូល និង ថែរក្សាទុកក្នុងទិន្នន័យរបស់ស្ថាប័នសាធារណៈផ្សេងៗ

ឃ- វិភាគ និង វាយតម្លៃនូវរាល់របាយការណ៍ប្រតិបត្តិការសង្ស័យនិងព័ត៌មានពាក់ព័ន្ធ ដើម្បីកំណត់ពីមូលដ្ឋានសមស្របដែលនាំឱ្យជឿជាក់ថាបទល្មើសសម្អាតប្រាក់ ឬបទល្មើសហិរញ្ញប្បទានភេរវកម្ម បានកើតឡើង ហើយក្នុងករណីនេះ បញ្ជូនសំណុំរឿងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស៊ើបអង្កេតពីបទល្មើស

ង- ចងក្រងស្ថិតិ និងកត់ត្រាអំពីរបាយការណ៍ប្រតិបត្តិការសង្ស័យនិងសាច់ប្រាក់ ដែលបានទទួល វិភាគ និងបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ច និងផ្តល់ព័ត៌មានទាំងនោះទៅស្ថាប័នសាធារណៈផ្សេងទៀត យោងតាមរឿងហេតុដែលពាក់ព័ន្ធ

ច- ផ្តល់មតិទៅបុគ្គលរាយការណ៍ និង ស្ថាប័នពាក់ព័ន្ធផ្សេងៗ នូវលទ្ធផលនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ ឬព័ត៌មានផ្សេងៗ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ឆ- ធានាថា រាល់ព័ត៌មានផ្ទាល់ខ្លួនដែលស្ថិតនៅក្នុងដៃរបស់ខ្លួន ត្រូវបានការពារមិនឱ្យបើកចំហដោយគ្មានការអនុញ្ញាត

ជ- ចាត់វិធានការ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីការងារទាក់ទងដល់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

ប្រការ ៣. ស.ហ.ក មានការិយាល័យចំនួន ៤ នៅក្រោមឱវាទ ហើយការិយាល័យទាំងនោះមានកម្រិតស្មើនឹងការិយាល័យនានានៅធនាគារជាតិនៃកម្ពុជា ។

១- ការិយាល័យច្បាប់ រដ្ឋបាល និង ព័ត៌មានវិទ្យា

២- ការិយាល័យវិភាគរបាយការណ៍

៣-ការិយាល័យតាមដានការប្រតិបត្តិ

៤- ការិយាល័យសហប្រតិបត្តិការ

ការិយាល័យ និង ផ្នែកនីមួយៗនៅក្រោមចំណុះ ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

ប្រការ ៩. ការិយាល័យច្បាប់ រដ្ឋបាល និងព័ត៌មានវិទ្យា មានមុខងារនិងភារកិច្ចជួយ ស.ហ.ក សម្របសម្រួល និងតាក់តែងលិខិតបទដ្ឋានគតិយុត្ត ការងាររដ្ឋបាលទូទៅ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា។ ការិយាល័យនេះរួមមាន ៣ ផ្នែក ដែលមានភារកិច្ចដូចតទៅ÷

១. ផ្នែកច្បាប់

- សហប្រតិបត្តិការជាមួយបញ្ញត្តិករ និង អាជ្ញាធរអាណាព្យាបាលបុគ្គលរាយការណ៍ ក្នុងការចេញផ្សាយសេចក្តីណែនាំរួមគ្នាអំពីកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ពិនិត្យឡើងវិញនូវសេចក្តីណែនាំដែលបានចេញផ្សាយ និងណែនាំបុគ្គលរាយការណ៍ពីរបៀបអនុវត្ត
- ផ្តល់ការប្រឹក្សាផ្លូវច្បាប់ និងបទប្បញ្ញត្តិ
- ពិនិត្យឡើងវិញពីគោលនយោបាយ និងសំណើដាក់ទណ្ឌកម្ម
- ណែនាំពីការរៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងក្នុងស្រុក និងអន្តរជាតិ
- តាក់តែងលិខិតបទដ្ឋានគតិយុត្ត

២. ផ្នែកព័ត៌មានវិទ្យា

- ស្វ័យប្រវត្តិកម្មការិយាល័យ (Office Automation)
- គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យារបស់ ស.ហ.ក
- ដោះស្រាយរាល់បញ្ហាដែលកើតឡើងនៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- ការពារប្រព័ន្ធឱ្យដំណើរការប្រក្រតី សុវត្ថិភាព និងទប់ស្កាត់មិនឱ្យអ្នកផ្សេងជ្រៀតចូលយកព័ត៌មានក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- គ្រប់គ្រងសំណុំរឿងជាក់ស្តែងតាមប្រព័ន្ធព័ត៌មានវិទ្យា (Electronic Case Management)

៣. ផ្នែករដ្ឋបាល

- ទទួល បញ្ជូនតាមមុខសញ្ញា និងរក្សាទុកនូវរាល់លិខិត ឬឯកសារដែលបានផ្ញើចូល
- ផ្គត់ផ្គង់សម្ភារៈ-មធ្យោបាយបម្រើការងារតាមសេចក្តីត្រូវការជាក់ស្តែង
- សហការ និងសម្របសម្រួលក្នុងការរៀបចំរបាយការណ៍ជូនក្រុមប្រឹក្សាភិបាល
- គ្រប់គ្រងបញ្ជីវត្តមានមន្ត្រីបុគ្គលិក
- រៀបចំកម្មវិធីការងារសម្រាប់ថ្នាក់ដឹកនាំ និងធានាពិធីការចំពោះភ្ញៀវនិងពិធីផ្សេងៗ
- ចូលរួមកសាងគម្រោងថវិកាប្រចាំគ្រាសម្រាប់ទ្រទ្រង់ដំណើរការអង្គភាពទាំងមូល
- រៀបចំរបាយការណ៍ប្រចាំគ្រារបស់ ស.ហ.ក
- ការគ្រប់គ្រងបញ្ជីបុគ្គលរាយការណ៍

- ការរក្សាសុវត្ថិភាពរបស់ ស.ហ.ក ។

ប្រការ ៥.- ការិយាល័យវិភាគរបាយការណ៍ មានមុខងារ និងភារកិច្ចទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ និងព័ត៌មានសង្ស័យផ្សេងៗ យកមកវិភាគ និងបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច ។ ការិយាល័យនេះមាន ២ ផ្នែក ដែលមានភារកិច្ចដូចតទៅ ÷

១. ផ្នែកទទួល និងវិភាគ

- ប្រមូល និងទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ ប្រតិបត្តិការសាច់ប្រាក់ និងព័ត៌មានផ្សេងទៀត
- ទទួលរបាយការណ៍អេឡិចត្រូនិកពីបុគ្គលរាយការណ៍
- ស្វែងរកព័ត៌មានបន្ថែម និងវិភាគរបាយការណ៍ប្រតិបត្តិការសង្ស័យ និងរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់
- បញ្ចូល រក្សាទុក និង ដំណើរការទិន្នន័យក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- ទំនាក់ទំនងជាមួយបុគ្គលរាយការណ៍

